7-3-22

03. 03. 2022

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងលេខ ២៩៣

ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

**សាលដីកា**

**លេខ:៤៩** ព្រ.ទ ក្រ.IV(1.ក)

ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

បានបង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦/០៧/២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ នាព្រឹកថ្ងៃសុក្រ ១១រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ដែលមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី. [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងសភាព្រហ្មទណ្ឌលេខ: ២៩៣ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ ដែលមាន៖

**ជនជាប់ចោទ:** ឈ្មោះ [redacted]ភួយ ហៅ ម៉ៅ ភេទប្រុស អាយុ ២៨ឆ្នាំ កើតនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៣ ជនជាតិខ្មែរ មុខរបរ ជាងឈើ កម្រិតវប្បធម៌ថ្នាក់ទី៣ ទីកន្លែងកំណើតភូមិស្នំ ឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម ទីលំនៅមុនពេលឃុំខ្លួននៅភូ[redacted]ខេត្តត្បូងឃ្មុំ។ ប្រពន្ធឈ្មោ[redacted]មាន កូន ០១នាក់ ឪពុកឈ្មោះ [redacted]ស់" ម្តាយឈ្មោះ [redacted]"ស្លាប់" ទោសពីមុនគ្មាន។ (ក្នុងឃុំ) (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ១២៧ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១( (ជាម្ចាស់បណ្តឹងឧទ្ធរណ៍)

- មានលោក[redacted]នុនីរង្ស ជាមេធាវីការពារសិទ្ធ។

ជាប់ចោទពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិជើងអង ឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-លោក [redacted] ប៊ុនហាវ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វីរៈ ។

-លោក [redacted] ឈុនឡេង ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វីរៈ ។

**ដើមបណ្តឹងរដ្ឋប្បវេណី**

១-ឈ្មោះ [redacted] ចិន ភេទប្រុស អាយុ៦២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិកូនសាត់ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។

២-ឈ្មោះ [redacted] ប៊ុនរ៉ុង ភេទប្រុស អាយុ៤៦ឆ្នាំជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិរលួសខាងកើត ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៧០ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ១១១៥ (ង) ព.ស.ព្រស ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ៤៥៣ ពស.ព្រជ (ក) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់លោកប្រធានសាលាដំបូងខេត្តសៀមរាប។

**ឯអង្គហេតុកើតមានឡើងដូចតទៅ:**

កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ០៨និង០០នាទី ស្ថិតនៅភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានករណីអំពើលួចដោយមានស្ថានទម្ងន់ទោស ដែលបង្កឡើងដោយជនមិនស្គាល់អត្តសញ្ញាណ បានធ្វើសកម្មភាពកាច់សោរម៉ូតូចំនួន ០១គ្រឿង ម៉ាក សង់សេ១២៥ ស៊េរីឆ្នាំ២០១៧ ពណ៌ខ្មៅ គ្មានស្លាកលេខ ដែលជារបស់ជនរងគ្រោះឈ្មោះ [redacted] ចិន ភេទប្រុស អាយុ៦២ឆ្នាំ ហើយបានជិះគេចខ្លួនបាត់ ។ លុះក្រោយមក សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ និងកំណត់មុខសញ្ញាឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] វីរៈ ភេទប្រុស អាយុ២៧ឆ្នាំ ព្រមទាំងដកហូតបានម៉ូតូខាងលើ និងអាវុធខ្លីចំនួន ០១ដើម ។

តំណាងអយ្យការនាពេលសវនាការ បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការ តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ជនជាប់ចោទបានសារភាពពិតជាមានអំពើលួចដោយមានស្ថានទម្ងន់ទោសប្រាកដមែន សូមតម្កល់បទចោទប្រកាន់ដូចនៅក្នុងដីកាសន្និដ្ឋានស្ថាពរលេខៈ ១៧០ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ របស់ អយ្យការអមសាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល។

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ លោក [redacted] ឈុនឡេង បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនបានសារភាពទោសកំហុស គឺសកម្មភាពកន្លងមកមានគ្នាចំនួន ០៤នាក់ តែពេលនេះទទួលតែពីរនាក់ទេ ដោយការធ្វើសកម្មភាព ឲ្យកូនក្តីខ្លួនជិះមកមុន ហើយពួកគេជិះតាមពីក្រោយទាន់ឲ្យទាំងម៉ូតូនិងអាវុធមកកូនក្តីរបស់ខ្លួន ។ ចំពោះសកម្មភាពកូនក្តីខ្លួន គឺទើបតែប្រព្រឹត្តបានម្តង ដូច្នេះស្នើសុំតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ានវ៉ា បានឆ្លើយថាៈ ខ្លួនពុំមានការខឹងឬគុំគួននឹងជនជាប់ចោទទេព្រោះក៏ជាសាច់ថ្លៃខ្លួនដែរ ប៉ុន្តែគ្រាន់តែខ្លួននៅរាងភ័យមិនទាន់បាត់នៅឡើយព្រោះនេះជាលើកទី១ដែលកើតឡើងសម្រាប់ខ្លួន។ ប្រសិនបើប្អូននៅតែគោរពខ្លួនជាបង ខ្លួនក៏នៅតែទទួលស្គាល់ និងទុកជាប្អូនដូចមុនដដែល។ ប្អូនខ្លួនពិតជាក្រីក្រមែន ។ ទាក់ទងនឹងការដាក់ពន្ធនាគារនេះគឺខ្លួនមិនដឹងទេស្រេចតែតុលាការទៅចុះច្បាប់កំណត់ថាផ្តន្ទាទោសប៉ុណ្ណាក៏ប៉ុណ្ណឹងទៅ និងស្នើសុំឲ្យរឿងនេះចប់ឆាប់ៗ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈឃើញថាជនជាប់ចោទបានទទួលស្គាល់នូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តគឺមានភាពស៊ីសង្វាក់គ្នានឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះខ្លួនស្នើសុំឲ្យសភាព្រហ្មទណ្ឌសម្រេចទៅតាមច្បាប់។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីខ្លួនបានសារភាពហើយថាគាត់ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហើយគាត់ពិតជាមានការសោកស្តាយ និងភ្ញាក់រលឹក និងបានសន្យាថាពេលចេញទៅមិនប្រព្រឹត្តបែបនេះទៀតទេ កូនក្តីខ្លួនរៀនបានតិចតួចជីវភាពក៏ក្រីក្រដូចដែលដើមបណ្តឹងបានបញ្ជាក់ហើយ ដូច្នេះខ្លួនស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផងទោះបីជាឃុំខ្លួនកូនក្តីខ្លួនយូរក៏ពុំទទួលបានលទ្ធផលអ្វីនោះដែរ ប្រពន្ធចេញទៅក្រៅរកស៊ី ឯកូនត្រូវយកទៅផ្ញើនឹងយាយគ្មានអ្នកមើលថែ។

- ជនជាប់ចោទបាននិយាយសំដីចុងក្រោយថាៈ ខ្លួនស្នើសុំឲ្យជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិការពារសិទ្ធិជនជាប់ចោទ
- ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## ២ សំអាងហេតុ

## សភាព្រហ្មទណ្ឌ យល់ឃើញថា

២-១. ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៤៤២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០២១ របស់ឈ្មោ[redacted]កូយ សុំប្តឹងនឹងសាលក្រមលេខៈ ២៦២ "ធ" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ត្រង់សេចក្តីសម្រេចទាំងមូល បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ អាចទទួលជំនុំជម្រះបានយោងតាមមាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-២. តាមសាលក្រមលេខៈ២៦២ "ធ" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តត្បូងឃ្មុំបានរកឃើញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ [redacted]កូយ ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិជើងអង ឃុំ កណ្តាលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងបញ្ញត្តិឱ្យផ្តន្ទា ទោសតាមមាត្រា២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ។

២-៣. នាពេលសវនាការជនជាប់ចោទបានលើកឡើងអំពីមូលហេតុនៃបណ្តឹងឧទ្ធរណ៍ថាខ្លួនប្តឹងឧទ្ធរណ៍ព្រោះតែខ្លួនមិនសុខចិត្តនឹងសាលក្រមរបស់សាលាដំបូងដែលបានសម្រេចផ្តន្ទាទោសខ្លួនច្រើនពេក ហើយជនជាប់ចោទក៏ដូចជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទក៏បានស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាផ្តល់ស្ថានសម្រាលដល់ជនជាប់ចោទផង ដោយបានលើកហេតុផលថាកូនក្តីខ្លួនបានសារភាពហើយថាគាត់ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហើយគាត់ពិតជាមានការសោកស្តាយ និងភ្ញាក់រលឹក និងបានសន្យាថាពេលចេញទៅមិនប្រព្រឹត្តបែបនេះទៀតទេ កូនក្តីខ្លួនរៀនបានតិចតួចជីវភាពក៏ក្រីក្រដូចដែលដើមបណ្តឹងបានបញ្ជា

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ លោក [redacted] ប៊ុនហាវ បានធ្វើសេចក្ដីសន្និដ្ឋានថា: កូនក្ដីរបស់ខ្លួនបានសារភាពកំហុស ស្នើសុំតុលាការមេត្តាពិចារណាបន្ធូរបន្ថយទោស ។

-បានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វីរៈ

-បានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន

-បានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនរ៉ុង

-បានពិនិត្យភស្ដុតាងនានា

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

**ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**យល់ឃើញថា**

-កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ថិតនៅត្រង់ចំណុចភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ឈ្មោះ [redacted] វីរៈ ពិតជាបានធ្វើសកម្មភាពប្រើប្រាស់អាវុធដោយខុសច្បាប់ និងលួចកាច់សោរកម៉ូតូមួយគ្រឿង ម៉ាកសង់សេ១២៥ ស៊េរីឆ្នាំ២០១៧ ពណ៌ខ្មៅ គ្មានស្លាកលេខ ដែលជារបស់ជនរងគ្រោះឈ្មោះ [redacted] ចិន ប្រាកដមែន ។

- ជនជាប់ចោទខាងលើ ពិតជាមានសមត្ថភាព មានស្មារតី និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវទង្វើរដែលខ្លួនបានប្រព្រឹត្ត ដូចការចោទប្រកាន់បញ្ជូនមកជម្រះរបស់ចៅក្រមស៊ើបសួរ តាមដីកាដំណោះស្រាយលេខៈ ១១១៥ (ង) ព.ស.ព្រស ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តសៀមរាប ។

-តាមភស្ដុតាង និងការពិនិត្យលើកិច្ចស៊ើបសួរ រហូតដល់ជម្រះមិនមានអង្គហេតុអ្វីប្រែប្រួលទេ។ ដូចនេះជនខាងលើពិតជាមានចេតនាក្នុងការប្រព្រឹត្តបទល្មើសនោះយ៉ាងពិតប្រាកដមែន តាមមាត្រា០៤ នៃក្រមព្រហ្មទណ្ឌ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះឈ្មោះ [redacted] ចិន ប៉ុន្តែជនរងគ្រោះបានទទួលទ្រព្យសម្បត្តិដែលបាត់បង់ពីជនជាប់ចោទរួចហើយ ហើយមិនបានចូលមកឆ្លើយទាមទាសំណងការខូចខាតនៅដំណាក់កាលស៊ើបសួរទេ ។ ដូចនេះតុលាការគប្បីមិនសម្រេចអំពីសំណងរដ្ឋប្បវេណីទេ។

-ចំពោះវត្ថុតាងរួមមាន: ទូរស័ព្ទដៃម៉ាក Camfone Model: P600 ពណ៌បៃតង ចំនួន ០១ គ្រឿង ,នាឡិកាដៃចំនួន ០១ និងសោរម៉ូតូម៉ាកហុងដា ចំនួន ០១ គប្បីតុលាការសម្រេចប្រគល់ឲ្យម្ចាស់ដើមឈ្មោះ [redacted] វីរៈ វិញ ។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted]: ភេទប្រុស អាយុ២៧ឆ្នាំ ពីបទៈ អំពើលួចដោយមានស្ថានទម្ងន់ទោស និងប្រើប្រាស់[redacted]ខុសច្បាប់ ប្រព្រឹត្តនៅភូមិរកាកំបុត ឃុំត្រពាំងធំ

ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ ,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និង មាត្រា៤៩០ នៃច្បាប់ស្តីពីអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

**<u>ហេតុដូច្នេះសម្រេច៖</u>**

១-ផ្តន្ទាទោសឈ្មោះ [redacted]រីះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ (ដូចមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ។

ពីបទ៖ អំពើលួចដោយមានស្ថានទម្ងន់ទោស និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ ,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៩០ នៃច្បាប់ស្តីពីអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

២-វត្ថុតាងរួមមានទូរស័ព្ទដៃម៉ាក Camfone Model: P600 ពណ៌បៃតង ចំនួន ០១គ្រឿង , នាឡិកាដៃចំនួន ០១ និងសោរម៉ូតូម៉ាកហុងដា ចំនួន ០១ ត្រូវប្រគល់ឲ្យម្ចាស់ដើមឈ្មោះ [redacted]រីះ វិញ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រីះ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន និងឈ្មោ[redacted]ប៊ុនរ៉ុង បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា[redacted] | ហត្ថលេខានិងត្រា[redacted] | ហត្ថលេខានិងត្រា: [redacted] | ហត្ថលេខានិងត្រា[redacted] |

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ០៦កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

សៀមរាប, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner